**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាង**

**រោងចក្រ ថប ស៊ីលវើរ លីមីធីត**

**និង**

**តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ**

**រោងចក្រ ថប ស៊ីលវើរ លីមីធីត**

**ស្ដីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង០១ និង ៣០នាទីព្រឹក នៅក្នុងក្រុមហ៊ុន ថប ស៊ីលវើរ លីមីធីត ( ស្វាយអន្ទរ ) មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងបច្ចុប្បន្នប្រឈមមុខខ្លាំងបញ្ហាជំងឺកូវីត-១៩ ដែលឥវ៉ាន់ដែលបានធ្វើរួចហើយត្រូវអ្នកបញ្ជាទិញមិនទាន់ទទួលយកតាមការកំណត់ ដោយហាងលក់ទំនិញភាគច្រើននៅបរទេសមិនទាន់បើកទ្វានៅឡើយទេ ដែលចំណុចទាំងអស់នេះធ្វើអោយផលិតកម្មមួយចំនួនធំមិនមានការងារធ្វើ តម្រូវអោយមានការព្យួរការងារ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ៣២៦នាក់ ចាប់ពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០២០ ។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករ និយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌដូចខាងក្រោម៖

- ចំនួន ១០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ចំនួន ២០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ០១ខែ។

អង្គប្រជុំបានចប់វេលាម៉ោង ០៣ និង៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន ។

ស្វាយអន្ទរ.ថ្ងៃទី២២ ខែមេសា ឆ្នាំ ២០២០

**តំណាងកម្មករ និង តំណាងសហជីព** | **នាយកក្រុមហ៊ុន**

PENG XIAO TING